បណ្ណសារដ្ឋានជាតិ
ថ្ងៃទី 11 ខែ 06 ឆ្នាំ 2003

# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១_ព្រះរាជក្រឹត្យ

២៧-៩-២០០១ ព្រះរាជក្រឹត្យនស/រកត/០៩០១/៣៣៥ស្តីពីការបំពាក់គ្រឿងឥស្សរិយយស**ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូនឯកឧត្តម **នូវ ការុន** អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ២៥៨០

២៧-៩-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣៣៦ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ដល់លោក **ដេងសាន ហាង** (DENG SHAN HUANG)ហៅ **ដេវីត**(DAVID )សញ្ជាតិដើមចិននៅកោះតៃវ៉ាន់ប្រទេសចិន ២៥៨១

២៧-៩-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣៣៧ ស្តីពីការផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយពម្ម ឋល់លោក **សូ ស៊ីមិញ** (ZHOU SHIMIN ) សញ្ជាតិដើមចិនកើតនៅខេត្តសេជាង(ZHEJIANG) ប្រទេសចិន ២៥៨២

២៨-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣៣៨ ស្តីពីការតែងតាំង:
១- ឯកឧត្តម **ឡុង សៀម** ជាប្រធានវិទ្យាស្ថានជាតិ
២-ឯកឧត្តម **រស់ ចន្ត្រាបុត្រ** ជាប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម ២៥៨៣

២៨-៩-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣៣៩ ស្តីពីការបំពាក់មេដាយ **ការពារជាតិ** ជូននាយទាហានជាន់ខ្ពស់ក្រៅក្របខ័ណ្ឌចំនួន ៥៧ រូប ក្នុង ០១រូបៗ សរិទ្ធ ០២គ្រឿង ប្រាក់០២គ្រឿង មាស ០២គ្រឿង ២៥៨៤

២៨-៩-២០០១ - ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣៤០ ស្តីពីការបំពាក់មេដាយ **ព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ជូនឯកឧត្តមចំនួន ០៦ រូបដែលមានស្នាដៃនិងគុណបំណាច់ខ្ពស់ក្នុងការបំរើប្រទេសជាតិ ២៥៨៨

២៩-៩-២០០១ -ព្រះរាជក្រឹត្យ នស/រកត/០៩០១/៣៤១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌគ្រូបង្រៀន កំរិតបឋម ២៥៨៩

## II- រាជរដ្ឋាភិបាល

### ១_អនុក្រឹត្យ

២៦-៩-២០០១ - អនុក្រឹត្យលេខ ៩៦ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៥៩៦

២៦-៩-២០០១ - អនុក្រឹត្យលេខ ៩៧ អនក្រ.បក ស្តីពីការផ្ទេរឥណទានថវិកា ២៥៩៨

២៧-៩-២០០១ - អនុក្រឹត្យលេខ ៩៨ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ២៦០០

២៧-៩-២០០១ - អនុក្រឹត្យលេខ ៩៩ អនក្រ.បក ស្ដីពីការរៀបចំសមាសភាពរចនាសម្ព័ន្ធតួនាទីភារកិច្ច និងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ២៦០២

២៨-៩-២០០១ - អនុក្រឹត្យលេខ ១០០ អនក្រ.បក ស្ដីពីការផ្ទេរឥណទានថវិកា ២៦០៩

២០-៩-២០០១ - អនុក្រឹត្យលេខ ៤១៧ អនក្រ.តត ស្ដីពីការតែងតាំងផ្លាស់ប្ដូរមុខងារនាយទាហាន ២៦១១

២០-៩-២០០១ - អនុក្រឹត្យលេខ ៤១៨ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ២៦១២

២៤-៩-២០០១ - អនុក្រឹត្យលេខ ៤១៩ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៦១៣

២៤-៩-២០០១ - អនុក្រឹត្យលេខ ៤២០ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ២៦១៥

២៦-៩-២០០១ - អនុក្រឹត្យលេខ ៤២១ អនក្រ.តត ស្ដីពីការតែងតាំងអភិបាលរងខេត្តសៀមរាប ០២ រូប ២៦១៧

២៧-៩-២០០១ - អនុក្រឹត្យលេខ ៤២២ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ២៦១៨

## III- ការងារបណ្ដាក្រសួង

### ១_ រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

២០-៩-២០០១ - សេចក្ដីសំរេចលេខ ៧១៣ មស ស្ដីពីការកែសំរួលនិងការបំពេញបន្ថែម សមាសភាពគណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការផ្នែកមុខងារសាធារណៈ ២៦១៩

### ២_ទីស្ដីការរដ្ឋមន្ត្រីក្រសួងពត៌មាន

២៦-៩-២០០១ - ប្រកាសលេខ ២៦៧ /០១ ពម ស្ដីពីការអនុញ្ញាតឱ្យអ្នកស្រី ខា រដ្ឋា បើកអាជីវកម្មរោងពុម្ព ឈ្មោះ ខា រដ្ឋា ស្ថិតនៅផ្ទះលេខ ២៩ BE₀ ផ្លូវលេខ ៣៥០ សង្កាត់បឹងកេងកង៣ ខ័ណ្ឌចំការមនរាជធានីភ្នំពេញ ២៦២០

### ៣_ទីស្ដីការរដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

២៦-៩-២០០១ - សារាចរលេខ ០៤ ក.ធ.ស .សរ.ស្ដីពីតួនាទីនិងភារកិច្ច-អាចារ្យ -គណៈកម្មការវត្ត ២៦២១

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣៣៥

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : បំពាក់គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **សេនា** ជូនឯកឧត្តម **នុង ភានុន** អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដែលមានស្នាដៃ និងគុណបំណាច់ខ្ពស់ក្នុងការបំរើប្រទេសជាតិ លើការងារស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខៈ ២៣៤ ៥.៧

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង គាង

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣៣៦

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ដេងសាន ហាង** ( DENG SHAN HUANG ) ហៅ **ដេវីត** ( DAVID ) សញ្ជាតិដើមចិន កើតថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ១៩៥០ នៅកោះតៃវ៉ាន់ ប្រទេសចិន ។

**មាត្រា ២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣** : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

រាជធានីភ្នំពេញ. ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខ: ៤៣៣ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible]

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣៣៧

យើង

ព្រះបាទសម្តេច ព្រះនរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១ :** ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់លោក **ស្ញ ស៊ីមិញ** ( ZHOU SHIMIN ) សញ្ជាតិដើមចិន កើតថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៥៥ នៅខេត្តសេជាង ( ZHEJIANG ) ប្រទេសចិន ។

**មាត្រា ២ :** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

**មាត្រា ៣ :** ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ៕

**ព្រះហស្ថលេខា**

**នរោត្តម សីហនុ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០១

លេខៈ ២៧៤ ច.ព

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សុខ ឈាន**

ណាន់ ឌី តាន់

នស/រកត/០៩០១/៣៣៨

# ព្រះរាជក្រឹត្យ

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : តែងតាំង :

១-ឯកឧត្តម ឡុង សៀម ជាប្រធានវិទ្យាស្ថានភាសាជាតិ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

២-ឯកឧត្តម រស់ ចន្ត្រាបុត្រ ជាប្រធានវិទ្យាស្ថានមនុស្សសាស្ត្រ និង វិទ្យាសាស្ត្រសង្គម មានឋានៈស្មើ អគ្គនាយក ។

**មាត្រា២** : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចព្រះរាជក្រឹត្យនេះ ។

**មាត្រា៣** : ព្រះរាជក្រឹត្យនេះ មានអានុភាពចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

លេខ: ៤៣៧ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ... ឆ្នាំ ២០០...

អគ្គលេខាធិការរាជរដ្ឋាភិបាល

[signature]

សុខ អាន

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០០១

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣៣៩

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយសនៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់សំណើរបស់ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ត្រូវបានបំពាក់មេដាយ ការពារជាតិ ជូននាយទាហានជាន់ខ្ពស់ក្រៅក្របខ័ណ្ឌចំនួន៥៧រូប ក្នុងមួយរូប១ សំរិទ្ធ០២គ្រឿង ប្រាក់០២គ្រឿង មាស០២គ្រឿង ដូចមានរាយនាមខាងក្រោម ÷

| | | | | |
|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ឯក | ណាធី | តាន់ | អត្តលេខ ០០០០៤៦ | អគ្គលេខាធិការ រាជរដ្ឋាភិបាល |
| ២-ឧត្តមសេនីយ៍ឯក | នា | ចំរើត | អត្តលេខ ០០០០០៧ | ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកការងារការពារសន្តិសុខសណ្តាប់ធ្នាប់ សំរាប់ការបោះឆ្នោតជាទូទៅ |
| ៣-ឧត្តមសេនីយ៍ឯក | ញឹក | ប៊ុនឆៃ | អត្តលេខ ០០០០០៩ | អនុប្រធានទី២ ព្រឹទ្ធសភា |
| ៤-ឧត្តមសេនីយ៍ឯក | ញឹម | វណ្ណដា | អត្តលេខ ០០០០១៩ | សមាជិក សភាមណ្ឌលព្រៃវែង |
| ៥-ឧត្តមសេនីយ៍ឯក | ទឹម | សេរ៉ាវណ្ណ | អត្តលេខ ០០០០៣៣ | អគ្គនាយកមជ្ឈមណ្ឌលកំចាត់មីន |
| ៦-ឧត្តមសេនីយ៍ឯក | អ៊ុំ | ម៉ាណូរិន | | អគ្គរាជទូត នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅសាធារណៈរដ្ឋប្រជាមានិត ប្រជាធិបតេយ្យកូរ៉េ |
| ៧-ឧត្តមសេនីយ៍ឯក | ប៊ូ | ហ៊ល | | ឧត្តមទីប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រ... |

| | | | | |
|---|---|---|---|---|
| ៨-ឧត្តមសេនីយ៍ឯក | អ៊ុង | ផន | | មន្ត្រីទីស្តីការគណៈរដ្ឋមន្ត្រី |
| ៩-ឧត្តមសេនីយ៍ឯក | ថាច់ | ផេង | អត្តលេខ ០០០០២៥ | ទីប្រឹក្សាព្រះប្រធានរដ្ឋសភា |
| ១០-ឧត្តមសេនីយ៍ឯក | ធន់ | ចាយ | អត្តលេខ ០០០០២៣ | |
| ១១-ឧត្តមសេនីយ៍ឯក | ស៊ឹម | តែង | អត្តលេខ ០០០០៣៧ | សមាជិក ព្រឹទ្ធសភា |
| ១២-ឧត្តមសេនីយ៍ឯក | ប៊ុល | ណាស់ | អត្តលេខ ០០០០៤៨ | សមាជិក ព្រឹទ្ធសភា |
| ១៣-ឧត្តមសេនីយ៍ឯក | នួន | សុខ | អត្តលេខ ០០០០១១ | សមាជិក សភាមណ្ឌលកំពង់ឆ្នាំង |
| ១៤-ឧត្តមសេនីយ៍ឯក | ដៀន | ដែល | អត្តលេខ ០០០០១៣ | សមាជិក សភាមណ្ឌលកណ្តាល |
| ១៥-ឧត្តមសេនីយ៍ឯក | ប៊ូ | ថង | អត្តលេខ ០០០០២២ | សមាជិក សភាមណ្ឌលរតនៈគីរី |
| ១៦-ឧត្តមសេនីយ៍ឯក | ឈឹម | ឌិមយ៉ុន | អត្តលេខ ០០០០២១ | ទីប្រឹក្សា រាជរដ្ឋាភិបាល |
| ១៧-ឧត្តមសេនីយ៍ទោ | ម៉ើង | ប៉ាត់ | អត្តលេខ ០០០០៥៥ | សមាជិកព្រឹទ្ធសភា |
| ១៨-ឧត្តមសេនីយ៍ទោ | ភួយ | ប៊ុនថា | អត្តលេខ ០០០១៧៦ | ខុទ្ទកាល័យសម្តេច ព្រឹទ្ធសភា |
| ១៩-ឧត្តមសេនីយ៍ទោ | ឃួន | ប្រាំង | អត្តលេខ ០០០០៤៥ | សមាជិក ព្រឹទ្ធសភា |
| ២០ ឧត្តមសេនីយ៍ទោ | ម៉ែន | សំអន | អត្តលេខ ០០១១៧៩ | សមាជិក សភាមណ្ឌលស្វាយរៀង |
| ២១-ឧត្តមសេនីយ៍ទោ | ហ៊ុល | សាច័ន្ទ | អត្តលេខ ០០០០៥២ | សមាជិក សភាមណ្ឌលស្វាយរៀង |
| ២២-ឧត្តមសេនីយ៍ទោ | តុល | ឡោះ | អត្តលេខ ០០០០៥៩ | ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងអប់រំ |
| ២៣-ឧត្តមសេនីយ៍ទោ | ឈឹម | សៀកឡេង | អត្តលេខ ០០០១៨៩ | ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ |
| ២៤ ឧត្តមសេនីយ៍ទោ | ចាប | គួនី | អត្តលេខ ០០០២៨៩ | ទីប្រឹក្សា ឯកឧត្តម អ៊ុង ហួត |
| ២៥-ឧត្តមសេនីយ៍ទោ | ហ៊ួត | ប៉ុំចលី | អត្តលេខ ០០១២៤៤ | សមាជិក សភាមណ្ឌលក្រចេះ |
| ២៦-ឧត្តមសេនីយ៍ទោ | ហាស | គ្រួច | អត្តលេខ ០០១១៧៧ | ខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា |
| ២៧-ឧត្តមសេនីយ៍ទោ | ហៀន | ចណ្ឌរ័ត្ន | អត្តលេខ ០០០០៦៦ | សមាជិក សភាមណ្ឌលតាកែវ |
| ២៨-ឧត្តមសេនីយ៍ទោ | មួង | សៅខន | អត្តលេខ ០០០១៧៥ | អនុរដ្ឋលេខាធិការមុខងារសាធារណៈ |
| ២៩-ឧត្តមសេនីយ៍ទោ | អ៊ុង | សាមី | អត្តលេខ ០០០០៦០ | អភិបាលខេត្ត ពោធិសាត់ |
| ៣០ ឧត្តមសេនីយ៍ទោ | ជៀង | អំ | អត្តលេខ ០០០០៦២ | អភិបាលខេត្ត កំពង់ចាម |
| ៣១-ឧត្តមសេនីយ៍ទោ | ព្រាប | តាន់ | អត្តលេខ ០០០០៩២ | អភិបាលខេត្ត ព្រះវិហារ |
| ៣២-ឧត្តមសេនីយ៍ទោ | អ៊ី | ឈាន | អត្តលេខ ០០៣៨០៤ | អភិបាលក្រុង ប៉ៃលិន៚ |

| | | | | |
|---|---|---|---|---|
| ៣៣-ឧត្តមសេនីយ៍ទោ | ម៉ៅ | ធីម | អត្តលេខ ០០០១៩៩ | អភិបាលរងទី១ ខេត្តឧត្តរមានជ័យ |
| ៣៤-ឧត្តមសេនីយ៍ទោ | អន | សុំ | អត្តលេខ ០០០០៣១ | អភិបាលរងទី១ខេត្តបន្ទាយមានជ័យ |
| ៣៥-ឧត្តមសេនីយ៍ទោ | ឌី | តិន | អត្តលេខ ០០១១៧៨ | មន្ត្រីក្រសួងសង្គមកិច្ច |
| ៣៦-ឧត្តមសេនីយ៍ទោ | កែច | សាផល | អត្តលេខ ០០០០៦៧ | អនុរដ្ឋលេខាធិការអាកាសចរស៊ីវិល |
| ៣៧-ឧត្តមសេនីយ៍ទោ | ថោង | នៅ | អត្តលេខ ០០០០៤៧ | ទីប្រឹក្សា សម្តេចក្រុមព្រះ |
| ៣៨-ឧត្តមសេនីយ៍ទោ | ដួច | ខែម | អត្តលេខ ០០០០៦៥ | |
| ៣៩-ឧត្តមសេនីយ៍ទោ | ឈឹម | ឈន | អត្តលេខ ០០០២០៣ | អភិបាលខេត្តស្ទឹងត្រែង |
| ៤០-ឧត្តមសេនីយ៍ត្រី | នុត | សុខុម | អត្តលេខ ០០០១៧៤ | សមាជិក សភាមណ្ឌលកណ្តាល |
| ៤១-ឧត្តមសេនីយ៍ត្រី | ឃុន | ពិសុប | អត្តលេខ ០០០១៩៩ | សមាជិក សភាមណ្ឌលកំពង់ចាម |
| ៤២-ឧត្តមសេនីយ៍ត្រី | មិន | សារឿន | អត្តលេខ ០០០២០០ | សមាជិកសភាមណ្ឌលបន្ទាយមានជ័យ |
| ៤៣-ឧត្តមសេនីយ៍ត្រី | ឃុត | សំអាន | អត្តលេខ ០០០១៩៦ | សមាជិកសភាមណ្ឌលបន្ទាយមានជ័យ |
| ៤៤-ឧត្តមសេនីយ៍ត្រី | ឡូ | ជី | អត្តលេខ ០០០២០១ | សមាជិក សភាមណ្ឌលរាជធានីភ្នំពេញ |
| ៤៥-ឧត្តមសេនីយ៍ត្រី | ឌ៉ុច | ឌី | អត្តលេខ ០០០១៣៧ | |
| ៤៦-ឧត្តមសេនីយ៍ត្រី | សុខ | សារឿន | | |
| ៤៧-ឧត្តមសេនីយ៍ត្រី | ថាច់ | សាច | អត្តលេខ ០០០១៦៩ | សមាជិកសភា មណ្ឌលកំពង់ស្ពឺ |
| ៤៨-ឧត្តមសេនីយ៍ត្រី | ឃិន | យ៉ាន | អត្តលេខ ០០០១៣៩ | អភិបាលខេត្ត ឧត្តរមានជ័យ |
| ៤៩-ឧត្តមសេនីយ៍ត្រី | អ៊ុំ | សារិទ្ធ | អត្តលេខ ០០១១៨៣ | ទីប្រឹក្សា សម្តេចប្រធានព្រឹទ្ធសភា |
| ៥០-ឧត្តមសេនីយ៍ត្រី | ភេរី | គុសល | អត្តលេខ ០០០១៩២ | សមាជិក ព្រឹទ្ធសភា |
| ៥១-ឧត្តមសេនីយ៍ត្រី | ហុង | ស៊ុនហួត | អត្តលេខ ០០០១៩០ | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល |
| ៥២-ឧត្តមសេនីយ៍ត្រី | ឌុ | ឌីអេដ៉ា | អត្តលេខ ០០០១៨១ | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល |
| ៥៣-ឧត្តមសេនីយ៍ត្រី | ហ៊ឹម | សារឿន | អត្តលេខ ០០១១៨០ | ទីប្រឹក្សាបច្ចេកទេស សាលាមធ្យមសិក្សាបច្ចេកទេស ឧស្សាហកម្ម |
| ៥៤-ឧត្តមសេនីយ៍ត្រី | ឈិ | ស៊ុ | អត្តលេខ ០០០១៩៩ | អភិបាលខេត្តកំពត |
| ៥៥-ឧត្តមសេនីយ៍ត្រី | ម៉ៅ | គិរុននេ | អត្តលេខ ០០០៣៩១ | អភិបាលរងទី២ ខេត្តកំពង់ចាម |
| ៥៦-ឧត្តមសេនីយ៍ត្រី | គត់ | ជ៉ាង | អត្តលេខ ០០០១៧៣ | ប្រចាំស្ថានទូតថៃ។ល។ |

៥៧-ឧត្តមសេនីយ៍ត្រី ហ៊ុន សីហួត អត្តលេខ ០០១១៨១ អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច និងការងារ

មាត្រា២ : នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។ល.ត.

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

លេខៈ ២៣៨ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០០១

រាជធានីភ្នំពេញថ្ងៃទី ០១ ខែតុលា ឆ្នាំ ២០០១

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊ុម ចាន់**

# ព្រះរាជក្រឹត្យ

នស/រកត/០៩០១/៣៤០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត ពិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប៉ះពាក់ **មេដាយព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម ចំនួន ០៦ រូប ដែលមានស្នាដៃ និង គុណបំណាច់ខ្ពស់ក្នុងការបំរើប្រទេសជាតិ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក-មេដាយព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា**

១-ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ជា ប្រធានក្រុមប្រឹក្សាសោយទ័ព

២-ឯកឧត្តម **ទៀ បាញ់** ទេសរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

**ខ-មេដាយព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ**

១-ព្រះអង្គម្ចាស់ **ស៊ីសុវត្ថិ សិរីរត្ន** សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

២-ឯកឧត្តម **ចាយ សាំងយុន** រដ្ឋលេខាធិការក្រសួងការពារជាតិ និង ជា ប្រធានគណៈកម្មការសោយទ័ព

**គ-មេដាយព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សឫទ្ធិ**

១-ឯកឧត្តម **ស្វាយ ស៊ីថា** អនុរដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និង ជាអគ្គលេខាធិការនៃក្រុមប្រឹក្សាសោយទ័ព

២-ឯកឧត្តម **មង់ រឿប** ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រី និង ជា សមាជិកក្រុមប្រឹក្សាសោយទ័ព

មាត្រា ២ : នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

[illegible]

បានជម្រាបជូន [illegible]

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ [illegible] ឆ្នាំ ២០០១

អគ្គលេខាធិការរាជរដ្ឋាភិបាល

# ព្រះរាជក្រឹត្យ
# ស្តីពីលក្ខន្តិកៈដោយឡែក
# នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម

នស/រកត/០៩០១/៣៤១

**យើង**

**ព្រះបាទសម្តេចព្រះនរោត្តមសីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/ ១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/ នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ដែលប្រកាសអោយប្រើច្បាប់ ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និង កីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍ទូទៅ នៃការរៀបចំបុគ្គលិកសាធារណៈរបស់រដ្ឋ
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំពីនាយករដ្ឋមន្ត្រី ដែលបានឯកភាពដោយគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០០១ ។

## គ្រាស់បន្ទាប់

## ជំពូក ទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

ត្រូវបានបង្កើតក្របខ័ណ្ឌ គ្រូបង្រៀនកំរិតបឋម ដែលត្រូវបានចាត់ថ្នាក់ក្នុងប្រភេទ គ ដូចមានចែងក្នុង មាត្រា៥ នៃព្រះរាជក្រឹត្យលេខ ជស-រកត ១២៩៧-២៧៣ ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ ។

**មាត្រា ២ .-**

ក្របខ័ណ្ឌ គ្រូបង្រៀនកំរិតបឋមស្ថិតក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា ប្រមូលផ្តុំគ្រប់មន្ត្រីបច្ចេកទេសខាងគរុកោសល្យ និង បច្ចេកទេស ផ្សេងទៀត ដែលបានបណ្តុះបណ្តាល ហើយកំពុងបំរើការនៅតាមគ្រឹះស្ថានសិក្សា សាធារណៈបឋមសិក្សា និងមត្តេយ្យសិក្សា និងតាមអង្គភាពជំនាញថ្នាក់កណ្តាល និង ខេត្ត ក្រុង នៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៣ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម មានមុខងារក្នុងតំណែង ជាអ្នកបង្រៀន អ្នកសិក្សាស្រាវជ្រាវនិងមុខងារក្នុងតំណែងគ្រប់គ្រង ។

## ជំពូក ទី ២
## ឋានន្តរស័ក្តិ និង មុខតំណែង

**មាត្រា ៤ .-**

ក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម មាន ៣ ឋានន្តរស័ក្តិ ÷

- ឋានន្តរស័ក្តិ ទី ១ ឬ គ្រូបង្រៀនកំរិតបឋម ដើមខ្សែពិសេស មាន ៦ ថ្នាក់
- ឋានន្តរស័ក្តិ ទី ២ ឬ គ្រូបង្រៀនកំរិតបឋម ដើមខ្សែ មាន ១០ ថ្នាក់
- ឋានន្តរស័ក្តិ ទី ៣ ឬ គ្រូបង្រៀនកំរិតបឋម មាន ១៤ ថ្នាក់ ។

**មាត្រា ៥ .-**

គ្រូបង្រៀនកំរិតបឋមមានឧបនិស្ស័យអាចកាន់មុខតំណែងគ្រប់គ្រងនៃក្រសួងអប់រំ យុវជន និងកីឡា ដូចខាងក្រោម ÷

- នាយករងសាលាបឋមសិក្សា
- នាយករងសាលាមត្តេយ្យសិក្សា។ល។

និងមុខតំណែងឯទៀតដែលមានថ្នាក់ស្មើនឹងមុខតំណែងខាងលើ ដែលមាននៅក្នុងអង្គការលេខនៃរចនាសម្ព័ន្ធរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៣
## ការជ្រើសរើស

**មាត្រា ៦ .-**

ការជ្រើសរើសចូលក្នុងក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម ត្រូវធ្វើឡើងតាមការប្រលងជ្រើសរើស ក្នុងចំណោមបេក្ខជនជាសិស្ស និស្សិត ។

ចំនួនតំណែងក្នុងការជ្រើសរើសសំរាប់បេក្ខជន ជាសិស្សនិស្សិត ត្រូវកំណត់ឡើងដោយរាជរដ្ឋាភិបាលតាមសំណើរបស់ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៧ .-**

ការប្រលងជ្រើសរើសក្នុងចំណោមសិស្សនិស្សិត ត្រូវបើកទូលាយចំពោះបេក្ខជនដែលមានអាយុច្រើនបំផុត ២៥ឆ្នាំ គិតមកដល់ថ្ងៃប្រលង ហើយដែលមានសញ្ញាប័ត្រទាបបំផុត សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឬ សញ្ញាប័ត្រសមមូល ។ អាយុនេះអាចរំកិលពី ២៥ ដល់ ៣០ ឆ្នាំ ស្របតាមមាត្រា១១ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

ការប្រលងជ្រើសរើសក្នុងចំណោមសិស្ស និស្សិត ត្រូវឆ្លងកាត់ការពិនិត្យសុខភាព និងកាយសម្បទាមុននឹងចូលរៀននៅសាលាបណ្តុះបណ្តាល ។

លក្ខណៈវិនិច្ឆ័យកាយសម្បទា ត្រូវកំណត់ដោយក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៤
## ការបណ្តុះបណ្តាលដំបូង កម្មសិក្សាសាកល្បង និង ការតាំងស៊ប់

**មាត្រា ៨ .-**

បេក្ខជនដែលបានជ្រើសរើសតាមរយៈការប្រលងជ្រើសរើស ក្នុងចំណោមសិស្សនិស្សិតមានឋានៈជាគរុសិស្សកំរិតបឋម ហើយត្រូវទទួលការបណ្តុះបណ្តាលដំបូងរយៈពេលខ្លីដែលរៀបចំដោយ ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៩ .-**

បន្ទាប់ពីការបណ្តុះបណ្តាលដំបូង គ្រូបង្រៀនកំរិតបឋម ត្រូវបានបែងចែកអោយទៅបំរើការងារនៅតាមខេត្ត ក្រុង ហើយត្រូវបានតែងតាំងជាគ្រូបង្រៀនកំរិតបឋម កម្មសិក្សាតាមប្រកាសរបស់ ក្រសួងអប់រំ./.

យុវជន និង កីឡា ។

គ្រូបង្រៀនកំរិតបឋមដែលជ្រើសរើសចេញពីសិស្ស និស្សិតត្រូវឆ្លងកាត់កម្មសិក្សាមួយដែលមានរយៈពេល១២ខែ ។ រយៈពេលកម្មសិក្សាត្រូវបានអនុវត្តចាប់ពីពេលប្រលងជ្រើសរើសជាប់ ។ក្រោយពេលធ្វើកម្មសិក្សាសាកល្បង មន្ត្រីដែលត្រូវបានជ្រើសរើសចេញពីសិស្សនិស្សិតត្រូវបានតាំងស៊ប់ក្នុងថ្នាក់លេខ ១៤ នៃឋានន្តរស័ក្តិ ទី ៣ ។

គ្រូបង្រៀនកំរិតបឋមដែលធ្វើកម្មសិក្សាធ្លាក់ត្រូវអនុញ្ញាតអោយបន្តកម្មសិក្សានៅឆ្នាំទី ២ទៀត ។ ក្នុងករណីធ្លាក់កម្មសិក្សានៅឆ្នាំទី ២ នេះកម្មសិក្សាការី ជ្រើសរើសចេញមកពីសិស្សនិស្សិត ត្រូវលុបឈ្មោះចោល ។

ការតាំងស៊ប់ក្នុងឋានន្តរស័ក្តិទី ៣ នៃគ្រូបង្រៀនកំរិតបឋម ត្រូវធ្វើឡើងដោយ ប្រកាស ។

## ជំពូក ទី ៥

## ការតែងតាំង

**មាត្រា ១០ .-**

ក្រោយពេលត្រូវបានតាំងស៊ប់ក្នុងក្របខ័ណ្ឌរួចហើយ គ្រូបង្រៀនកំរិតបឋមត្រូវបានតែងតាំងអោយបំពេញមុខងារក្នុង មុខតំណែង ដូចមានចែងក្នុងមាត្រា ៣ ឬ អាចត្រូវបានតែងតាំងក្នុងមុខតំណែងគ្រប់គ្រងទំនេរណាមួយ ដូចមានចែងក្នុងមាត្រា៥ ខាងលើ ។

## ជំពូក ទី ៦

## ការដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម

**មាត្រា ១១ .-**

គ្រូបង្រៀនកំរិតបឋម អាចដាក់អោយស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬក្រៅតំណែងដើម្បីបំរើការនៅក្រសួងស្ថាប័នមួយផ្សេងទៀតតាមតំរូវការ និងតាមការយល់ព្រមពីសាមីជន ។

## ជំពូក ទី ៧

## ការតម្លើងថ្នាក់ និង ការតម្លើងឋានន្តរស័ក្តិ

**មាត្រា ១២ .-**

គ្រូបង្រៀនកំរិតបឋម ត្រូវបានតម្លើងថ្នាក់ក្នុងឋានន្តរស័ក្តិណាមួយ ទៅតាមលក្ខខណ្ឌដូចបានចែងក្នុងមាត្រា ២០ និង មាត្រាបន្តបន្ទាប់ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ។

លក្ខណៈសម្បត្តិជាមូលដ្ឋាន ដែលត្រូវពិនិត្យតម្លើងថ្នាក់មានដូចខាងក្រោម ÷

- គំនិតផ្តួចផ្តើមច្នៃប្រឌិត និង លទ្ធផលការងារ
- មនសិការវិជ្ជាជីវៈ ស្មារតីទទួលខុសត្រូវ វិន័យការងារ៕ល៕

- ការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ជាតិ
- សាមគ្គីភាព សីលធម៌រស់នៅ សកម្មភាពសង្គម ។

ការតម្លើងថ្នាក់ នៃអ្នករាជការក្នុងក្របខ័ណ្ឌនេះ ត្រូវគិតក្នុងសមាមាត្រ ៣ ភាគ ៤ ក្នុងវេនជ្រើសរើស និង ១ ភាគ ៤ តាមវេនអតីតភាព ។

**មាត្រា ១៣ .-**

គោលការណ៍ នៃការតម្លើងឋានន្តរស័ក្តិ ត្រូវតែតម្លើងទៅក្នុងថ្នាក់ដំបូង នៃឋានន្តរស័ក្តិខ្ពស់លើបន្ទាប់ ឬក្នុងករណីចាំបាច់ ត្រូវតែតម្លើងទៅក្នុងថ្នាក់ដែលស្របជាមួយសន្ទស្សន៍ខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់មន្ត្រីសាមី ។

ការតម្លើងឋានន្តរស័ក្តិ ត្រូវអនុវត្ត តាមគោលការណ៍ភាគរយ ដោយត្រូវបានកំណត់ តាមសមាមាត្រ ៧០% សំរាប់ឋានន្តរស័ក្តិទី៣ ២៥%សំរាប់ឋានន្តរស័ក្តិទី២ និង៥%សំរាប់ឋានន្តរស័ក្តិទី១ ។ ការតម្លើងឋានន្តរស័ក្តិនេះត្រូវធ្វើតាមរយៈការចុះឈ្មោះក្នុងតារាងតម្លើងឋានន្តរស័ក្តិ និងការវាយតំលៃរបស់ឋានានុក្រម គ្រប់គ្រង ឬតាមរយៈការបណ្តុះបណ្តាល និងវិក្រឹតការជំនាញនៅក្នុង ឬ ក្រៅប្រទេស ។

ការតម្លើងថ្នាក់ និង តម្លើងឋានន្តរស័ក្តិ នៃគ្រូបង្រៀនកំរិតបឋម ត្រូវសំរេចដោយប្រកាសរបស់ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ១៤ .-**

អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតបឋមដើមខ្សែ គឺ គ្រូបង្រៀនកំរិតបឋមទាំងឡាយដែលបានឡើង ដល់ថ្នាក់ លេខ ១១ ឡើងទៅក្នុងឋានន្តរស័ក្តិទី ៣ នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម ។ អាចតម្លើងទៅក្នុងឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតបឋមដើមខ្សែពិសេស គឺគ្រូបង្រៀនកំរិតបឋមទាំងឡាយដែលបានឡើងដល់ថ្នាក់លេខ ៧ ឡើងទៅនៃឋានន្តរស័ក្តិ គ្រូបង្រៀនកំរិតបឋមដើមខ្សែ ។

**មាត្រា ១៥ .-**

សន្ទស្សន៍សំរាប់ថ្នាក់ក្នុងឋានន្តរស័ក្តិនីមួយៗ នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម និង តំលៃឯកតានៃសន្ទស្សន៍ ព្រមទាំងកំរិត លាភការផ្សេងៗទៀត ត្រូវកំណត់ដោយព្រះរាជក្រឹត្យដោយឡែក ។

## ជំពូក ទី ៨
## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦ .-**

ក្នុងករណីចាំបាច់ លក្ខខ័ណ្ឌដោយឡែក នៃការប្រលងជ្រើសរើសគ្រូបង្រៀនកំរិតបឋមសំរាប់ខេត្ត ក្រុង ដាច់ស្រយាល និងតំបន់ជួបការលំបាកត្រូវកំណត់ដោយរាជរដ្ឋាភិបាល ។ល។

**មាត្រា ១៧ .-**

មន្ត្រីរាជការក្នុងក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម ត្រូវទទួលប្រាក់កំរៃគរុកោសល្យ ជាប្រាក់រង្វាន់នៃមុខតំណែងគ្រូបង្រៀន ។

**មាត្រា ១៨ .-**

គ្រូបង្រៀនកំរិតបឋមដែលក្រសួងចាត់អោយទៅទទួលការបំប៉ន ឬការបណ្តុះបណ្តាលបន្តរយៈពេលសរុបយ៉ាងតិច ៦ ខែ នៅក្នុងជំនាញ ដែលបំរើអោយវិស័យអប់រំ យុវជន និង កីឡា ដោយមានវិញ្ញាបនប័ត្រ ឬលិខិតបញ្ជាក់ការសិក្សាត្រូវបានទទួលការតម្លើងថ្នាក់ ១ ថ្នាក់ ជាស្វ័យប្រវត្តិតាមវេនជ្រើសរើស ។

ចំពោះគ្រូបង្រៀនកំរិតបឋម ដែលត្រូវបានក្រសួងចាត់អោយទៅបន្តសិក្សា ឬ បំប៉នជំនាញផ្សេងៗ រយៈពេលសិក្សានោះត្រូវបានគិតសំរាប់ការតម្លើងឋានន្តរស័ក្តិ ឬ ឡើងថ្នាក់ ។

**មាត្រា ១៩ .-**

ពេលចូលបំរើការដំបូង ឬ ក្នុងពេលបំរើការ គ្រូបង្រៀនកំរិតបឋមដែលមានសញ្ញាប័ត្រខ្ពស់ជាងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ត្រូវបានតម្លើងថ្នាក់ជាស្វ័យប្រវត្តិ ១ ថ្នាក់ សំរាប់សញ្ញាប័ត្រមធ្យមសិក្សាបច្ចេកទេស និង ២ ថ្នាក់ សំរាប់បរិញ្ញាប័ត្រ ឬ សញ្ញាប័ត្រសមមូល ។

**មាត្រា ២០ .-**

គ្រូបង្រៀនកំរិតបឋម បំរើការរហូតដល់អាយុ ៦០ ឆ្នាំ ទើបចូលនិវត្តន៍ ។

ការដាក់អោយចូលនិវត្តន៍ ត្រូវសំរេចដោយប្រកាសរបស់ក្រសួង អប់រំ យុវជន និង កីឡា ។

## ជំពូក ទី ៩

## អន្តរប្បញ្ញត្តិ

**មាត្រា ២១ .-**

ចំនួនមន្ត្រី នៃក្របខ័ណ្ឌគ្រូបង្រៀនកំរិតបឋម ត្រូវកសាងចេញពីសមាហរណកម្ម គ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សាប្រភេទ ខ III ដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែង និងមុខងារពិតប្រាកដរបស់ក្របខ័ណ្ឌ ក្នុងគ្រឹះស្ថានសិក្សាសាធារណៈនិងក្នុងអង្គភាពជំនាញថ្នាក់កណ្តាល និងតាម ខេត្ត ក្រុង របស់ក្រសួងអប់រំ យុវជន និង កីឡា ។

ដោយឡែក ចំពោះគ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សា ប្រភេទ ខ IV ក្រសួងអប់រំ យុវជន និង កីឡា ត្រូវរៀបចំអោយមានការប្រលងផ្ទៃក្នុង ១ ឆ្នាំម្តង ទៅជាគ្រូបឋមសិក្សា និងគ្រូមត្តេយ្យសិក្សាប្រភេទ ខ III ។ ការប្រលងផ្ទៃក្នុងនេះត្រូវអនុវត្តអោយចប់ក្នុងរយៈពេល ៣ ឆ្នាំ គិតពីពេលព្រះរាជក្រឹត្យនេះ ចូលជាធរមាន ។

អ្នកប្រលងជាប់ត្រូវធ្វើសមាហរណកម្មទៅក្របខ័ណ្ឌគ្រូបង្រៀនបឋមសិក្សា ។ អ្នកប្រលងធ្លាក់ទាំង ៣ លើក ត្រូវធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌប្រភេទ ឃ របស់មុខងារសាធារណៈ ។៸។

មាត្រា ២២ .-

គ្រូបង្រៀនកីឡាបឋម ដែលត្រូវបានតែងតាំងរួចហើយ ក្នុងមុខតំណែងគ្រប់គ្រងណាមួយត្រូវបាន អនុញ្ញាតអោយបន្តមុខតំណែងរបស់ខ្លួន លើកលែងតែមានការចាំបាច់ ត្រូវផ្លាស់ប្តូរមុខតំណែងដែលជាសមត្ថកិច្ច របស់ក្រសួង អប់រំ យុវជន និង កីឡា។

## ជំពូក ទី ១០

## អវសានប្បញ្ញត្តិ

មាត្រា ២៣ .-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៤ .-

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជ ក្រឹត្យនេះ ។

មាត្រា ២៥ .-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។/.

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ ២០០១

ព្រះហស្តលេខា

នរោត្តម សីហនុ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

លេខ៧៣៥ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០០១

អគ្គលេខាធិការរងនៃរាជរដ្ឋាភិបាល

[illegible] ភាន់

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_______

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ...៩១... អនក្រ . បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ១.៥០០ លានរៀល ( មួយពាន់ប្រាំរយលានរៀលគត់ ) ពីជំពូក ៤០ ( ចំណាយផ្សេងៗ ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ទីស្តីការគណៈរដ្ឋមន្ត្រី សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ចំណាយដំណើរការរដ្ឋបាលដែលខ្វះក្នុងឆ្នាំ ២០០១ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីជំរាបជូន**
**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ...៩៧...អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ២៥ លានរៀល ( ម្ភៃប្រាំលានរៀលគត់ ) ពីជំពូក ៤១ (ចំណាយឥតគ្រោងទុក ) នៃខ្ទង់ចំណាយមិនទាន់បែងចែក មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) របស់ព្រឹទ្ធសភា សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើង ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សំរាប់ចំណាយថែទាំ និង ដំណើរការរថយន្ត ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សម្តេចប្រធានព្រឹទ្ធសភា ត្រូវ ទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ២៦ ខែ ៩ ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ . ឯកសារ

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីស្តីទី

អ៊ុក រ៉ាប៊ុន

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៩៨ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានថវិកា ចំណាយតាមជំពូក នៃច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ៤០០ លានរៀល ( បួនរយលានរៀលគត់ ) ពីជំពូក ៣២ ( អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា ) មកជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច) របស់ក្រសួងទេសចរណ៍ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់ការបោះពុម្ភ,ការផ្សាយ និង ឃោសនាអំពីទេសចរណ៍ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

រដ្ឋមន្ត្រីស្តីទី

អ៊ុក រ៉ាប៊ុន

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការរៀបចំសមាសភាព រចនាសម្ព័ន្ធ តួនាទីភារកិច្ច និងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការងារចាំបាច់របស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ

## សំ រេ ច

## ជំពូកទី ១

## អំពីសមាសភាព របស់ក្រុមប្រឹក្សា ស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និង ជនបទ ហៅកាត់ថា "គកជ ឬ CARD"

**មាត្រា ១.**

សមាសភាពនៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានដូចតទៅ ÷

- នាយករដ្ឋមន្ត្រី ប្រធាន

| | |
|---|---|
| - ឥស្សរជនមួយរូបមានឋានៈស្មើរដ្ឋមន្ត្រី | អនុប្រធាន |
| - អនុប្រធានទី ១ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងធនធានទឹក និង ឧតុនិយម | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងបរិស្ថាន | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងផែនការ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងសាធារណការ និង ដឹកជញ្ជូន | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងដែនដីនគរូបនីយកម្ម និង សំណង់ | សមាជិក |
| - រដ្ឋមន្ត្រី ឬ តំណាងក្រសួងកិច្ចការនារី និង អតីតយុទ្ធជន | សមាជិក |
| - អគ្គទេសាភិបាលធនាគារជាតិ នៃកម្ពុជា ឬ តំណាង | សមាជិក |
| -ប្រធានឧត្ដមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬ តំណាង | សមាជិក |
| - ប្រធានធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |
| - ប្រធានមូលនិធិកាត់បន្ថយភាពក្រីក្រ | សមាជិក |
| - អគ្គលេខាធិការ ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ | សមាជិក |
| - អគ្គនាយកមូលនិធិសង្គមនៃព្រះរាជាណាចក្រកម្ពុជា | សមាជិក |
| - មេបញ្ជាការ-បញ្ជាការដ្ឋានវិស្វកម្មនៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ | សមាជិក |

## ជំពូកទី ២
## អំពីរចនាសម្ព័ន្ធរបស់ "គកជ ឬ CARD"

**មាត្រា ២.**

បង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ "ក.ក.ជ" ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់អគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។

អគ្គលេខាធិការដ្ឋាននៃគកជ មានផ្នែកជំនាញចំនួន ៨ ដោយមានមន្ត្រីឯកទេសបំរើការ ÷

- ផ្នែក រដ្ឋបាល
- ផ្នែក ផ្គត់ផ្គង់ និងហិរញ្ញវត្ថុ
- ផ្នែក កសិកម្ម រួមមានៈ ចិញ្ចឹមសត្វ សំភារៈគ្រឿងយន្ត និងធនធានមនុស្ស ។ល។
- ផ្នែក កៅស៊ូ
- ផ្នែក អភិវឌ្ឍន៍ជនបទ
- ផ្នែក អាជីវកម្មព្រៃឈើ និងជលផល
- ផ្នែក ធនធានទឹក (បំរើការងារស្រោចស្រព)
- ផ្នែក ផែនការ និងសហប្រតិបត្តិការអន្តរជាតិ

**មាត្រា ៣.**

អគ្គលេខាធិការមានឋានៈស្មើ រដ្ឋលេខាធិការ អគ្គលេខាធិការរងមានឋានៈស្មើ អនុរដ្ឋលេខាធិការ និងផ្នែកនីមួយៗ មានឋានៈស្មើនាយកដ្ឋានហើយដឹកនាំដោយប្រធានមួយរូប ។

**មាត្រា ៤.**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ (កកជ) មានគណៈកម្មាធិការប្រតិបត្តិមួយសំរាប់ដឹកនាំការងារប្រចាំថ្ងៃ ។

គណៈកម្មាធិការប្រតិបត្តិនៃ (កកជ) រួមមានសមាសភាពដូចតទៅ ÷

១- ប្រធាន "កកជ"

២- អនុប្រធាន "កកជ"

៣- អគ្គលេខាធិការ "កកជ"

៤- អគ្គលេខាធិការរង "កកជ"

## ជំពូកទី ៣
## អំពីតួនាទី និង ភារកិច្ចរបស់ "កកជ ឬ CARD"

**មាត្រា ៥.**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានតួនាទីជាគណៈបញ្ជាការឯកភាពមួយ ជំនួយការអោយរាជរដ្ឋាភិបាល ក្នុងវិស័យស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ដោយសហការគ្នាយ៉ាងជិតស្និទ្ធជាមួយបណ្តាក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ពន្ធ័ ជាពិសេសជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងធនធានទឹក និងឧតុនិយម ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដើម្បីអនុវត្តអោយស៊ីសង្វាក់ប្រទាក់ក្រឡាគ្នា និងមានប្រសិទ្ធភាព

ព្រមទាំងមានសិទ្ធិសំរេចអំពីមធ្យោបាយ សំភារៈ ទុន និងការងារផ្សេងៗទៀតដែលជួយអោយសំរេចរាល់ភារកិច្ច ដែលមានចែងក្នុងមាត្រា ៦។

**មាត្រា ៦.**

ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ មានភារកិច្ចដូចខាងក្រោម :

- ទទួលបន្ទុកចាត់ចែងតាមដាន និងផ្តល់យោបល់លើការអនុវត្តន៍នូវកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងកម្មវិធីជាតិនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា ចំពោះកិច្ចការស្តារនិងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ សំដៅប្រែក្លាយវិស័យកសិកម្មដែលមានទំលាប់ធ្វើ ដើម្បីផ្គត់ផ្គង់ខ្លួនឯងអោយទៅជាការផលិតដើម្បីនាំចេញ ព្រមទាំងបន្ថយជាជំហានៗនូវគម្លាតឆ្ងាយរវាងជនបទ និងទីក្រុង
- កំណត់កត្តាគន្លឹះទាំងឡាយដែលបំរើអោយការស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ។
- កំណត់អាទិភាព និងកម្មវិធីនយោបាយក្នុងការស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទអោយសមស្របតាមគោលនយោបាយនៃរាជរដ្ឋាភិបាល
- ចលនា និងសំរបសំរួលការចូលរួមយ៉ាងកុះករពីប្រជារាស្ត្រ ជាពិសេសក្រុមហ៊ុនឯកជន សហគមន៍ជនបទ អង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល ជាមួយក្រសួង-ស្ថាប័ន ខេត្ត-ក្រុង ដើម្បីបង្កនូវភាពងាយស្រួល និងភាពសហការគ្នាល្អក្នុងការស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទដើម្បីធានាផលិតកម្ម និងអាជីវកម្មដោយនិរន្តរភាព និងធានាសន្តិសុខស្បៀង កាត់បន្ថយភាពក្រីក្រនៅជនបទ
- ពិនិត្យផ្តល់យោបល់ ដោះស្រាយរាល់សំណើដែលបានស្នើសុំពីក្រសួង-ស្ថាប័ន ដែលពាក់ពន្ធ័ដល់ការស្តារ និងអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។ រាយការណ៍ និងសុំយោបល់រាជរដ្ឋាភិបាលលើបញ្ហាសំខាន់ៗ ដែលស្ថិតក្នុងសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល។

## ជំពូកទី ៤

## ដំណើរការប្រព្រឹត្តិទៅរបស់ " គកជ ឬ CARD "

**មាត្រា ៧.**

ប្រធាន "គកជ" មានតួនាទី និងភារកិច្ចដូចតទៅ ÷

- ទទួលខុសត្រូវលើការងាររបស់ "គកជ"
- ធ្វើជាអធិបតីភាពក្នុងអង្គប្រជុំរបស់ "គកជ" និងអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ "គកជ"

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី______ខែ______ឆ្នាំ_______

- ដឹកនាំពិភាក្សា និងបូកសរុបមតិសំរេចរបស់អង្គប្រជុំពេញអង្គ "កកជ" និងអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិរបស់ "កកជ"
- កោះប្រជុំសាមញ្ញ ឬ ក្នុងករណីចាំបាច់ប្រជុំវិសាមញ្ញនៃអង្គប្រជុំ "កកជ" និងអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ "កកជ" ។

## មាត្រា ៨.

អនុប្រធាន "កកជ" មានតួនាទី និងភារកិច្ចដូចតទៅ :

- ទទួលខុសត្រូវជាទូទៅលើការងារ "កកជ" ក្នុងករណីប្រធានអវត្តមាន
- ទទួលខុសត្រូវក្នុងការដឹកនាំ និងគ្រប់គ្រងការងារប្រចាំថ្ងៃរបស់ "កកជ"
- ធ្វើជាអធិបតីនៃអង្គប្រជុំ "កកជ" និងអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ "កកជ" និងចុះហត្ថលេខាលើកំណត់ហេតុ និងលើសេចក្តីជូនដំណឹងនៃអង្គប្រជុំរបស់ "កកជ"
- ទទួលបន្ទុកការងារសំរបសំរួលអន្តរក្រសួងរវាង "កកជ" ជាមួយក្រសួង-ស្ថាប័ន នៃរាជរដ្ឋាភិបាល
- ទទួលបន្ទុកទំនាក់ទំនងជាមួយភាគីបរទេស ដែលពាក់ពន្ធ័ក្នុងការងារស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ ។

## មាត្រា ៩.

អគ្គលេខាធិការ "កកជ" មានតួនាទី និងភារកិច្ចដូចតទៅ ÷

- ទទួលបន្ទុកចាត់ចែងគ្រប់គ្រងការងាររបស់អគ្គលេខាធិការដ្ឋាននៃ "កកជ"
- រៀបចំកម្មវិធីរបស់ "កកជ" និងរៀបចំរបៀបវារៈ និងសំណុំឯកសារផ្សេងៗសំរាប់អង្គប្រជុំរបស់ "កកជ" និងអង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ "កកជ"
- រៀបចំកំណត់ហេតុ សេចក្តីជូនដំណឹងអង្គប្រជុំនៃ "កកជ" និងអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ "កកជ" ដើម្បីដាក់ជូនអនុប្រធាន "កកជ" ចុះហត្ថលេខា
- រៀបចំរបាយការណ៍ "កកជ" ប្រចាំត្រីមាស ប្រចាំឆមាស ឬ ប្រចាំឆ្នាំ
- រៀបចំប្រកាសពត៌មានរបស់ "កកជ"
- ចូលរួមប្រជុំ "កកជ" និងអង្គប្រជុំគណៈកម្មាធិការប្រតិបត្តិ "កកជ"
- បំពេញការងារផ្សេងៗទៀតដែលប្រធាន និងអនុប្រធាន "កកជ" ប្រគល់អោយ ។

## មាត្រា ១០.

អគ្គលេខាធិការរងនីមួយៗ បំពេញកិច្ចការតាមភារកិច្ច ដែលអគ្គលេខាធិការប្រគល់អោយ ។

## មាត្រា ១១.

សមាជិក "កកជ" មានតួនាទី និងភារកិច្ចដូចតទៅ :

- ចូលរួមប្រជុំសាមញ្ញ និងវិសាមញ្ញនៃអង្គប្រជុំរបស់ "គកជ" ដើម្បីពិនិត្យសំរេចរាល់សំណើរបស់ស្ថាប័នដែលពាក់ពន្ធ័ដល់ការស្តារអភិវឌ្ឍន៏វិស័យកសិកម្ម និងជនបទ
- សមាជិកដែលជាប្រធានស្ថាប័ន មានសមត្ថកិច្ចពាក់ពន្ធ័ដល់ការស្តារអភិវឌ្ឍន៏វិស័យកសិកម្ម និងជនបទ មានភារកិច្ចលើកកម្មវិធី នយោបាយរបាយកាណ៏ វិធានការ សំណើផ្សេងៗមក "គកជ" ដើម្បីពិនិត្យសំរេច
- ពិនិត្យសំរេចលើរបាយការណ៏របស់ "គកជ" ប្រចាំត្រីមាស ប្រចាំឆមាស ឬ ប្រចាំឆ្នាំ ។

**មាត្រា ១២.**

"គកជ" ត្រូវកោះប្រជុំសាមញ្ញយ៉ាងយូរ បីខែម្តង ។

**មាត្រា ១៣.**

គណៈកម្មាធិការប្រតិបត្តិនៃ "គកជ" ត្រូវកោះប្រជុំសាមញ្ញពីរសប្តាហ៏ម្តង ។

**មាត្រា ១៤.**

"គកជ" មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬ តំណាងស្ថាប័ន ឬ ទីប្រឹក្សាតាមការចាំបាច់ ដើម្បីចូលរួមប្រជុំ "គកជ" ឬ ប្រជុំគណៈកម្មាធិការប្រតិបត្តិ "គកជ" ។

**មាត្រា ១៥.**

អនុប្រធាន "គកជ" និង អគ្គលេខាធិការ "គកជ" មានសិទ្ធិចូលរួមប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី តាមការអញ្ជើញរបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**មាត្រា ១៦.**

រាល់សកម្មភាពរដ្ឋបាល ថវិកាចំណាយរបស់ "គកជ" ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗ របស់មន្ត្រីរាជការជាបន្ទុករបស់ទីស្តីការគណៈរដ្ឋមន្ត្រី។

**មាត្រា ១៧.**

ក្នុងករណីចាំបាច់ប្រធាន "គកជ" អាចនឹងកោះប្រជុំវិសាមញ្ញរបស់ "គកជ" និងប្រជុំវិសាមញ្ញនៃគណៈកម្មាធិការប្រតិបត្តិនៃ "គកជ" ។

**មាត្រា ១៨.**

ការប្រព្រឹត្តិទៅនៃអង្គប្រជុំរបស់ "គកជ" អង្គប្រជុំរបស់គណៈកម្មាធិការប្រតិបត្តិ ការរៀបចំ និងការប្រព្រឹត្តិទៅនៃអគ្គលេខាធិការដ្ឋាន "គកជ" ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ "គកជ" ។

**មាត្រា ១៩.**

"កកជ" មានសិទ្ធិប្រើត្រារបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**មាត្រា ២០.**

អនុក្រឹត្យលេខ ៥៦ / អនក្រ.បក / ចុះថ្ងៃ ទី១១ ខែកក្កដា ឆ្នាំ១៩៩៥ អនុក្រឹត្យលេខ ៧៩ / អនក្រ.បក / ចុះថ្ងៃ ទី២៩ ខែ ធ្នូ ឆ្នាំ១៩៩៨ និងអនុក្រឹត្យលេខ ៩៥ / អនក្រ.បក / ចុះថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ២០០០ និងបទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២១.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួង សាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍ វិស័យកសិកម្ម និង ជនបទ ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តតាមខ្លឹមសារនៃអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចម្លងជូន :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១
- ឯកសារ - កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១០០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការផ្ទេរឥណទានថវិកា

************

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ , ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ , ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ , ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ , ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ហើយត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១នស/៩៤ , ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និង ត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ , ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩
- បានឃើញព្រះរាជក្រម នស/រកម/១២០០/១២ , ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក , ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការបែងចែកឥណទានចំណាយថវិកាចំណាយ តាមជំពូកនៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ ២០០១
- បានឃើញអនុក្រឹត្យលេខ ០៣ អនក្រ.បក , ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០១ ស្តីពីការផ្ទេរឥណទានថវិកា
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

## សំរេច

**មាត្រា១:** ត្រូវបានអនុញ្ញាតិអោយផ្ទេរឥណទានថវិកា ចំនួន ១៨៧ លានរៀល (មួយរយប៉ែតសិបប្រាំពីរលានរៀលគត់) ពីជំពូក ១១ (ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់តូច) មកជំពូក ៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា) របស់ក្រសួងពាណិជ្ជកម្ម សំរាប់ការគ្រប់គ្រងឆ្នាំ ២០០១ ។

**មាត្រា២:** ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកទាំងនេះ តាមប្រការ កថាខ័ណ្ឌ និង វាក្យខ័ណ្ឌ ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរាប់បង់វិភាគទានជូនអង្គការអន្តរជាតិផ្សេងៗ ។

**មាត្រា៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**ចំលងជូន**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- កាលប្បវត្តិ - ឯកសារ

**បានយកសេចក្តីគោរពជូន**

**សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា**

**គាត ឈន់**

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ:** ៤១៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការតែងតាំងផ្លាស់ប្តូរមុខងារនាយទាហាន
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត **ក្រសួងការពារជាតិ**
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- យោងតាមសំណើរបស់ សហរដ្ឋមន្ត្រី **ក្រសួងការពារជាតិ**

**<u>ស ម្រេ ច</u>**

**<u>មាត្រា១</u>** : ត្រូវបានតែងតាំងផ្លាស់ប្តូរមុខងារ នាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម ÷

១-វរសេនីយ៍ឯក គឹម គន្ធា អត្តលេខ ០០២៤៦៧ នាយសេនាធិការរង និងជាមេបញ្ជាការព្រលានយន្តហោះពោធិចិនតុង កងទ័ពជើងអាកាស បច្ចុប្បន្នជា នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន

២-វរសេនីយ៍ឯក ម៉ៅ សាវួន អត្តលេខ ០០០៣១៩ នាយសេនាធិការរងយោធភូមិភាគទី២ បច្ចុប្បន្នជា មេបញ្ជាការរង យោធភូមិភាគទី២

៣-វរសេនីយ៍ឯក សុខ យាន អត្តលេខ ០០០៨៥៧ មេបញ្ជាការរង អង្គរក្សសម្តេចនាយករដ្ឋមន្ត្រី បច្ចុប្បន្នជា ទីប្រឹក្សាអគ្គមេបញ្ជាការ

**<u>មាត្រា២</u>** : រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈអគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាម៉ីខ្លួនដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

ហ៊ុន សែន

<u>ចម្លងជូន</u>
ក្រសួងព្រះបរមរាជវាំង
អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋានរដ្ឋសភា
ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
ដូចមាត្រា២
ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៩១៧ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់អភិបាលខេត្តកំពង់ស្ពឺ

## សំរេច

**មាត្រា ១** : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ប្រគេន និង ជូនសប្បុរសជន ០២ រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ វត្តអង្គតាឡឹក នៅក្នុងឃុំសំបូរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ ÷

១-ព្រះតេជគុណ **អ៊ឹម អ៊ិន** ព្រះចៅអធិការវត្តអង្គតាឡឹក បច្ច័យចំនួន ៤២.៥០៧ ដុល្លារអាមេរិក

២-លោក **ខេន សុភា** នាយកក្រុមហ៊ុន ខេន សុភា អាហារ៍ណ នីហារ៍ណ និង ដឹកជញ្ជូនទឹកប្រាក់ចំនួន ១២៨.៩៨៣ ដុល្លារអាមេរិក

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល** :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៨១.៩៧...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រុមប្រឹក្សាវិសាយកងកម្លាំងប្រដាប់អាវុធ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** តាមលំដាប់ថ្នាក់ ជូនតំណាងប្រទេសផ្តល់ជំនួយសំរាប់កម្មវិធីវិសាយកងកម្លាំងប្រដាប់អាវុធ ដូចមានរាយនាមខាងក្រោមនេះ ÷

**ក‑ មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ**

| | |
|---|---|
| ១-HE. Mr. Bonaventure MBIDA- ESSAMA | ប្រធានក្រុមប្រទេសផ្តល់ជំនួយវិសាយទ័ព |
| ២-HE. Mr. GOTARO OGAWA | ឯកអគ្គរាជទូតជប៉ុន |
| ៣-HE. Mr. JAN NORDLANDER | ឯកអគ្គរដ្ឋទូតស៊ុយអែត |
| ៤-HE. Mr. GERARD J.H.CH. KRAMER | ឯកអគ្គរាជទូតហូឡង់ |
| ៥-HE. Dr. HARALD LOESCHNER | ឯកអគ្គរដ្ឋទូតសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ |
| ៦-HE. Mr. KENT WIEDEMANN | ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក |
| ៧-HE. Mr. NORMAND MAILHOT | ឯកអគ្គរដ្ឋទូតកាណាដា |

ខ-មេដាយសហមេត្រី ថ្នាក់ សេនា

១-Mr. MASAKI KAWAGUCHI លេខាទី ២ ឯកអគ្គរាជទូតជប៉ុន

២-Mr. DANIEL ASPLUND មេធាវីឯកអគ្គរដ្ឋទូតស៊ុយអែត

៣-Mr. CEES KIEFT លេខាទី ១ ឯកអគ្គរាជទូតហូឡង់

៤-Mrs. REBECCA HANSEN នាយកកម្មវិធីស្បៀងអាហារពិភពលោក

៥-Mr. SERGEI STADNITSKI ទីប្រឹក្សាលទ្ធកម្មនិងភស្តុភារនៃក្រុមប្រឹក្សារំសាយទ័ព

**មាត្រា ២** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រុមប្រឹក្សារំសាយកងកម្លាំងប្រដាប់អាវុធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល** :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ-ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា**    **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខ: ៤២០ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពីការជូនមេដាយការងារ

* * * * *

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការ បង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ក្រុមប្រឹក្សារំសាយកងកម្លាំងប្រដាប់អាវុធ

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនក្រុមប្រឹក្សារំសាយកងកម្លាំងប្រដាប់អាវុធ ចំនួន ១១ រូប ដែលមានស្នាដៃ និង គុណបំណាចខ្ពស់ ក្នុងការបំរើប្រទេសជាតិ ដូចមានរាយនាមខាងក្រោមនេះ ÷

១-ឧត្តមសេនិយទោ **លី ដេត** ប្រធានក្រុមការងាររបស់គណៈកម្មការរំសាយទ័ព

២-ឧត្តមសេនិយទោ **មាស សាវ៉ន** ប្រធានក្រុមការងាររបស់គណៈកម្មការរំសាយទ័ព

៣-ឧត្តមសេនិយទោ **ផន ណារ៉ា** ប្រធានក្រុមការងាររបស់គណៈកម្មការរំសាយទ័ព

៤-ឧត្តមសេនិយទោ **ជាំ ធុន្នី** សមាជិកគណៈកម្មការរំសាយទ័ព

៥-ឧត្តមសេនិយទោ **មាស សំអុល** សមាជិកគណៈកម្មការរំសាយទ័ព

៦-ឧត្តមសេនិយត្រី **អ៊ួន លន** សមាជិកគណៈកម្មការរំសាយទ័ព

៧-លោក **ខៀវ ឆេន** អគ្គលេខាធិការរងនៃក្រុមប្រឹក្សារំសាយទ័ព

៨-លោក **ព្រាំ សំអុល** អគ្គលេខាធិការរងនៃក្រុមប្រឹក្សារំសាយទ័ព

៩-លោក **ប៉ុក ធារី** អគ្គលេខាធិការរងនៃក្រុមប្រឹក្សារំសាយទ័ព

១០-លោក **ឌោង សុជាតិ** ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ អគ្គលេខាធិការដ្ឋាន

១១-លោក **សុខ ធី** ប្រធានមជ្ឈមណ្ឌលកុំព្យូទ័រអគ្គលេខាធិការដ្ឋាន

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង ក្រុមប្រឹក្សាសាយកងកម្លាំងប្រដាប់អាវុធ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ ២០០១

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- កាលប្បវត្តិ ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៩២១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការតែងតាំងអភិបាលរងខេត្តសៀមរាប

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំ រេ ច

**មាត្រា ១** : ត្រូវបានតែងតាំងអភិបាលរងខេត្តសៀមរាប ចំនួន ០២ រូប ដូចមានរាយនាមខាងក្រោម ÷

១- លោក ច័ន្ទ សុផល   ២- លោក ចេង លឹមស្រៀង

**មាត្រា ២** : បទបញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ , ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០០១*

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៣*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៩២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសហមេត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការប្រកាសប្រើគ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពត៌មាន

## សំរេច

**មាត្រា ១ :** ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោក **KOJI KAGOMIYA** ជំនាញការ **JICA** ជប៉ុនប្រចាំអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា ដែលបានជួយផលិតកម្មវិធីទូរទស្សន៍ ព្រមទាំងជួយផ្តល់នូវយុទ្ធសាស្ត្រ និង យុទ្ធវិធីគ្រប់គ្រងការផលិត និងការផ្សាយ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០១*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចក្នុងមាត្រា ១ និងមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ_កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈរដ្ឋមន្ត្រី**

**រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ**

លេខ : ៤/១៣ អ.សរ.

## សេចក្តីសម្រេច
### ស្តីពី
### ការកែសម្រួល និងការបំពេញបន្ថែមសមាសភាពគណៈកម្មាធិការជាតិ សម្រាប់កិច្ចសហប្រតិបត្តិការ ផ្នែកមុខងារសាធារណៈ

### រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ ០៦ នស ៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦.២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- បានឃើញ អនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំគណៈកម្មាធិការជាតិទាំង៦ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកមិនរាល់
- យោងលិខិតលេខ ៥៨១ មស ចុះថ្ងៃទី ០៧ ខែ កក្កដា ឆ្នាំ ១៩៩៩
- យោងលិខិត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លេខ ៣១២ សហវ.ប ចុះថ្ងៃទី ២០ កក្កដា ឆ្នាំ ២០០១
- យោងលិខិត ក្រសួងពាណិជ្ជកម្ម លេខ ២៤៦២ MoC/M 2001 ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០១

## សំរេច

**ប្រការ១** : កែសំរួល និងបំពេញបន្ថែម សមាសភាពគណៈកម្មាធិការជាតិ សំរាប់កិច្ចសហប្រតិបត្តិការ ផ្នែកមុខងារសាធារណៈ ដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១. | ឯកឧត្តម | **ពេជ្រ ប៊ុនធិន** | រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ប្រធាន |
| ២. | ឯកឧត្តម | **មាស គីមហេង** | អគ្គនាយក នៃអគ្គនាយកដ្ឋានអាស៊ានកម្ពុជា តំណាង ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធានប្រចាំការ |
| ៣. | ឯកឧត្តម | **អ៊ុក បាយ** | អនុរដ្ឋលេខាធិការ តំណាងក្រសួងផែនការ | សមាជិក |
| ៤. | ឯកឧត្តម | **សក់ សេដ្ឋា** | អគ្គនាយក តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ៥. | លោក | **ហុង ឆរ៉ាំនាន** | ប្រធាននាយកដ្ឋាន តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦. | លោក | **រស់ បរម** | អនុប្រធាននាយកដ្ឋាន តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧. | លោក | **ឃឹម សិរីវឌ្ឍ** | អនុប្រធាននាយកដ្ឋាន តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |

**ប្រការ២** : គ្រប់ក្រសួងពាក់ព័ន្ធ និងសាមីខ្លួន មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

ធ្វើនៅភ្នំពេញ ថ្ងៃទី ១៣ ខែ កញ្ញា ឆ្នាំ ២០០១

រដ្ឋលេខាធិការ

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល** :
- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី ដើម្បីជូនជ្រាប
- ដូចប្រការ ២
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពត៌មាន**
**MINISTRY OF INFORMATION**
លេខ ៤៦៧/០១ ព.ម

រាជធានីភ្នំពេញ , ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០០១

## ប្រកាស
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨.៧២ ចុះថ្ងៃទី៣០.១១.១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស.រកម ០១៩៦.១៤ ចុះថ្ងៃទី២៤.០១.១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពត៌មាន
- បានឃើញអនុក្រឹត្យលេខ៧០ អនក្រ.បក ចុះថ្ងៃទី០៥.០៨.១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពត៌មាន
- យោងលិខិតស្នើសុំច្បាប់បើកអាជីវកម្មរោងពុម្ពចុះថ្ងៃទី២១.០៩.២០០១ របស់អ្នកស្រី ជា រដ្ឋា ។

**<u>សំរេច</u>**

**<u>ប្រការ១</u>:** អនុញ្ញាតអោយអ្នកស្រី ជា រដ្ឋា បើកអាជីវកម្មរោងពុម្ពឈ្មោះ " ជា រដ្ឋា " ស្ថិតនៅផ្ទះលេខ ២៩ BE₀ ផ្លូវលេខ ៣៩០ សង្កាត់បឹងកេងកង៣ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ ។

**<u>ប្រការ២</u>:** រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យា សមស្របតាមទំនៀម ទំលាប់ប្រពៃណីខ្មែរ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

**<u>ប្រការ៣</u>:** ក្នុងករណីប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងប្រការ២ សាម៉ីខ្លួនត្រូវទទួលខុសត្រូវតាមច្បាប់ជាធរមាន ។

**<u>ប្រការ៤</u>:** នាយកដ្ឋានសោតទស្សន៍ នៃក្រសួងពត៌មាន មន្ទីរពត៌មានរាជធានីភ្នំពេញ សាម៉ីខ្លួន និងអាជ្ញាធរដែលពាក់ព័ន្ធត្រូវទទួលអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**<u>ប្រការ៥</u>:** ប្រកាសនេះមានសុពលភាព រយៈពេល១ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី**

<u>ចម្លងជូន</u>
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- សាលាក្រុងភ្នំពេញ " ដើម្បីជ្រាបជាពត៌មាន "
- នាយកដ្ឋានសោតទស្សន៍ នៃក្រសួងពត៌មាន
- មន្ទីរពត៌មានរាជធានីភ្នំពេញ " ដើម្បីអនុវត្ត "
- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
លេខ ០៤ ក.ធ.ស សរ

# សារាចរ
## ស្តីពីតួនាទី និង ភារកិច្ច អាចារ្យ-គណៈកម្មការវត្ត

**យោង :**
- ព្រះរាជក្រិត្យលេខ នសរកត ១១៩៨-៧២ ,ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា ។
- ព្រះរាជក្រមលេខ នសរកម ០១៩៦-១៩ ,ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធម្មការ និង សាសនា ។
- អនុក្រិត្យលេខ ១៣ អនក្រ-បក ,ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការ និង សាសនា ។
- ស្មារតីអង្គប្រជុំ,នាថ្ងៃទី១០ខែកញ្ញាឆ្នាំ២០០១ របស់ ថ្នាក់ដឹកនាំនាយកដ្ឋាននិងមន្ទីរធម្មការនិងសាសនា ខេត្ត កណ្តាល,តាកែវ,កំពង់ស្ពឺ ស្តីពីតួនាទី និង ភារកិច្ច របស់ អាចារ្យនិងគណៈកម្មការវត្ត។

អនុលោមតាមស្មារតី នៃអនុសំវច្ឆរៈមហាសន្និបាតមន្ត្រីសង្ឃលើទី ១០ កាលពីថ្ងៃទី ២៩-៣០-៣១ ខែ ឧសភា ឆ្នាំ ២០០១ បានដាក់ចេញនូវ សង្ឃប្រកាសរួមដើម្បីឱ្យមន្ត្រីសង្ឃទូទៅព្រមទាំង មន្ទីរធម្មការ និង សាសនា គ្រប់ខេត្ត-ក្រុង ដើម្បីគោរពប្រតិបត្តិព្រះពុទ្ធសាសនា ដោយយកព្រះវិន័យជាធំ ដែលជាបន្ទាត់ ធ្វើឱ្យកាន់តែសុក្រឹតតាមពុទ្ធប្បញ្ញត្តិ និង ពុទ្ធានុញ្ញាតិ ។

កន្លងទៅក៏ដូចជាបច្ចុប្បន្ន ក្រសួងធម្មការ និង សាសនា តែងបានសង្កេតឃើញថា : អធិករណ៍ ចេះតែកើតមានទ្វេរនិងរីករាលដាលច្រើនឡើងៗ នៅក្នុងបណ្តាវត្តមួយចំនួនទូទាំងប្រទេសបណ្តាលមកពីមូលហេតុជាច្រើនក្នុងនោះផ្តើមចេញពីគណៈកម្មការនិងអាចារ្យវត្តអនុវត្តពុំទាន់បាននូវភារកិច្ចរបស់ខ្លួនជាអ្នកជំនួយការដល់គណៈសង្ឃ ក្នុងការគ្រប់គ្រងដឹកនាំវត្តឱ្យមានសណ្តាប់ធ្នាប់របៀបរៀបរយសមរម្យជាកន្លែងគោរពសក្ការៈរបស់ពុទ្ធបរិស័ទ គ្រប់ៗរូប ដូច្នេះដើម្បីរំងាប់នូវអធិករណ៍ទាំងនេះ និងជៀសវាងឱ្យផុតអំពីបាតុភាពអសកម្មដែលធ្វើឱ្យប៉ះពាល់ ដល់កិត្តិយសសេចក្តីថ្លៃថ្នូ នៃព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ក្រសួងសូមធ្វើការណែនាំដូចតទៅនេះ ។

## រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

សូមជំរាប លោកនាយក លោកស្រីនាយិការ នៃ មន្ទីរធម្មការ និង សាសនា គ្រប់ខេត្ត-ក្រុង បានជ្រាបថា : ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការថែរក្សា និងគ្រប់គ្រង នូវគុរុភណ្ឌវត្ត ឱ្យបានគង់វង្សល្អប្រសើរ ក៏ដូចជាការរៀបចំ ពិធីការបុណ្យទាន ដែលមាននៅក្នុងអារាម ជាប្រក្រតីនោះ ឱ្យត្រឹមត្រូវហ្មត់ចត់តាម ពុទ្ធប្បញ្ញត្តិ និង ពុទ្ធានុញ្ញាត ក្រសួងសូមធ្វើការបែងចែកតួនាទី និង ភារកិច្ច របស់អាចារ្យ និង គណៈកម្មការ ឱ្យបានច្បាស់លាស់ដូចតទៅនេះ ។

### I-**អំពីអាចារ្យ**

វត្តនិមួយៗ ត្រូវមានអាចារ្យម្នាក់ និងអាចារ្យរង គឺជាអ្នកចាំទទួលបង្គាប់បញ្ជាពីគណៈសង្ឃវត្តក្នុងគ្រប់ភារកិច្ច និងការងាររបស់វត្តទាំងអស់ ។

ចំពោះអាចារ្យមានអាណត្តិ ៣ ឆ្នាំហើយត្រូវជ្រើសរើសដោយគណៈសង្ឃវត្ត (ចៅអធិការ) និងមន្ត្រីការិយាល័យធម្មការ ស្រុក-ខ័ណ្ឌ ចេញពីចំណោមព្រឹទ្ធាចារ្យ ឧបាសក ឧបាសិកា ជើងវត្តនោះទាំងអស់ដែលបាន

មកធ្វើទានរក្សាសីលជាប្រចាំនៅក្នុងវត្ត ហើយត្រូវបានចេះធម៌ច្បាស់លាស់ ព្រមទាំងមានអត្តចរិតស្លូតបូត រាបសារ គឺជាគ្រូទ្ធាចារ្យគំរូ ព្រមទាំងជាអ្នកមានសមត្ថភាពយល់ដឹងផ្នែកពិធីការព្រះពុទ្ធសាសនាច្បាស់លាស់ ។

បេក្ខជន-បេក្ខនារី ម្នាក់ៗ ( ទាំងពីរផ្នែក) ត្រូវបំពេញសំណុំបែបបទដូចខាងក្រោម :

ក-ពាក្យសុំឈរឈ្មោះ ១ ច្បាប់

ខ-ប្រវត្តិរូបសង្ខេប ៤ ច្បាប់

គ-កិច្ចសន្យា ( តាមគំរូ ) ១ ច្បាប់

ឃ-រូបថត ៤ x ៦ ៤ សន្លឹក

<u>អំពីតួនាទី និង ភារកិច្ចអាចារ្យ</u> :

-ជំនួយក្នុងការដឹកនាំពុទ្ធបរិស័ទធ្វើបុណ្យផ្សេងៗ តាមប្រពៃណីព្រះពុទ្ធសាសនា ទាំងនៅក្នុងនិង ក្រៅវត្ត តាមសេចក្តីត្រូវការ ។

-ជំនួយការទំនាក់ទំនងបរិស័ទក្នុងនិងក្រៅវត្ត ព្រមទាំងអប់រំ និងផ្សព្វផ្សាយទ្រឹស្តីព្រះពុទ្ធសាសនា ។

-ជំនួការក្នុងការទប់ស្កាត់នឹងរំងាប់នូវអធិករណ៍ទាំងឡាយដែលកើតមានឡើងនៅក្នុងវត្តជាយថាហេតុ

## II- <u>អំពីគណៈកម្មការវត្ត</u>

វត្តទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជា ចាំបាច់ត្រូវតែមានគណៈកម្មការមួយក្រុមដែលមានប្រធាន អនុប្រធាននិងសមាជិកច្រើនឬតិចទៅតាមទំហំការងារ ។ ទន្ទឹមនិងនោះដែរ គណៈកម្មការនោះត្រូវជ្រើសរើស ដោយការបោះឆ្នោត ក្នុងចំណោមគ្រូទ្ធាចារ្យ ឧបាសក ឧបាសិកា និងពុទ្ធបរិស័ទចំណុះជើងវត្តនោះផ្ទាល់ ទាំងអ្នក បោះឆ្នោត ឬអ្នកឈរឈ្មោះឱ្យគេបោះឆ្នោត គឺអ្នកមានអាស័យដ្ឋានពិតប្រាកដអចិន្ត្រៃយ៍នៅជើងវត្តនោះដែលមក សមាទានសីល ហើយជាមនុស្សមានកិរិយា មាយាទ ស្លូតបូតរាបសារ ស្មោះត្រង់និងព្រះពុទ្ធសាសនាមានសមត្ថភាព គ្រប់គ្រាន់ស្រឡាញ់ផលប្រយោជន៍រួម សកម្មការងារហើយត្រូវបាន ព្រះសង្ឃនិងពុទ្ធបរិស័ទ មានជំនឿជឿ ជាក់ថាជាជនគំរូ ។ ជាពិសេសបេក្ខជនឬបេក្ខនារីម្នាក់ៗ ត្រូវបានគណៈសង្ឃវត្តនិងប្រធានការិយាល័យ ធម្មការស្រុក-ខ័ណ្ឌ ទទួលស្គាល់ព្រមទាំងបញ្ជាក់ប្រវត្តិរូបនិងកិរិយាមាយាទពីអាជ្ញាធរដែនដី ច្បាស់លាស់ ។

<u>អំពីតួនាទី និង ភារកិច្ចគណៈកម្មការ</u> :

គណកម្មការវត្តមានអាណត្តិ ៣ ឆ្នាំ គឺ ជាអ្នកជំនួយការឱ្យគណៈសង្ឃ និងអាចារ្យវត្ត គ្រប់ការងារចាំ បាច់របស់វត្តនីមួយៗ តាមការប្រគល់ ឬ បញ្ជាពីគណៈសង្ឃ ដោយសហការជាមួយអាចារ្យវត្តផងដែរ ហើយដែល មាននាទី និងភារកិច្ចដូចមាន រាយខាងក្រោមនេះ :

- ជំនួយការឱ្យគណៈសង្ឃក្នុងការទំនាក់ទំនងការងាររដ្ឋបាលជាមួយអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ។
- ជំនួយការឱ្យគណៈសង្ឃក្នុងការថែរក្សាសម្បត្តិគរុភ័ណ្ឌវត្ត ។
- ជំនួយការឱ្យគណៈសង្ឃក្នុងការផ្គត់ផ្គង់ចង្ហាន់ព្រះសង្ឃ ។
- ជំនួយការឱ្យគណៈសង្ឃក្នុងការត្រួតពិនិត្យព្រះសង្ឃព្រមទាំងអ្នកស្នាក់នៅ និងរក្សានូវសុវត្ថិភាព ក្នុងវត្តទាំងមូល ។
- ជំនួយការឱ្យគណៈសង្ឃវត្តក្នុងការសាងសង់សំណង់ផ្សេងៗ និងកែលំអរសោភ័ណ្ឌភាពវត្តឱ្យ បាន សមរម្យជាទីកន្លែងគោរពសក្ការៈ ។
- ជំនួយការសហការរៀបចំពិធីបុណ្យប្រពៃណីក្នុងវត្ត ។
- ជំនួយការឱ្យគណៈសង្ឃជាពិធីករក្នុងពេលមានកម្មវិធីបុណ្យផ្សេង ៗ ទាំង តូច-ធំ ។

អាចារ្យនិងគណៈកម្មការវត្តនិមួយៗ គឺជាអ្នកជំនួយការដល់ព្រះសង្ឃក្នុងវត្ត ។ ចំពោះបច្ច័យនិង សំភារៈគរុភ័ណ្ឌរបស់វត្ត គឺគណៈកម្មការជាអ្នកទុកដាក់ តែក្រោមការត្រួតពិនិត្យរបស់គណៈសង្ឃវត្ត សហការជាមួយ អាចារ្យសំរេចទាំងអស់គ្នានូវចំណូលនិងចំណាយ ។

អំពីលក្ខណៈជ្រើសរើសទាំង អាចារ្យ និង គណៈកម្មការ ត្រូវធ្វើការបោះឆ្នោតដោយចំហរ ឬ សម្ងាត់ តាមសភាពជាក់ស្តែងក្រោមអធិបតីភាព គណៈសង្ឃវត្ត និង មន្ត្រីធម្មការនិងសាសនា ខ័ណ្ឌ-ស្រុក ។ ចំពោះបេក្ខជន ទាំងពីរផ្នែកនេះត្រូវបានកំណត់អាយុពី ៤០ ឆ្នាំ ឡើងទៅ ។ ឯអ្នកដែលមានសិទ្ធិបោះឆ្នោត គឺឧបាសក ឧបាសិការ ដែលបានមកសមាទានសីល ជាប្រចាំក្នុងវត្ត ជាពុទ្ធបរិស័ទចំណុះជើងវត្តនោះផ្ទាល់ ហើយមានអាស័យដ្ឋាន អចិន្ត្រៃយ៍

បណ្ណសារដ្ឋានជាតិ
ថ្ងៃទី_____ខែ_____ឆ្នាំ_____

នៅទីនោះផង ។ ក្រោយពីបានទទួលពាក្យស្នើសុំឈរឈ្មោះគ្រប់សព្វហើយនោះគណៈសង្ឃវត្ត និងមន្ត្រីធម្មការ ខ័ណ្ឌ-ស្រុក ធ្វើការប្រកាសជូនដំណឹងជាសាធារណៈនូវឈ្មោះ បេក្ខជន-បេក្ខនារី មុន ១៥ ថ្ងៃ ទើបធ្វើការបោះឆ្នោត ។ គណៈសង្ឃវត្តមានសិទ្ធិស្នើសុំដកហូតអាចារ្យ ឬ គណៈកម្មការវត្តចេញពីដំណែង បានតាមការប្រព្រឹត្ត មិនប្រក្រតីរបស់គេដោយមានការចូលរួមពីមន្ត្រីការិយាល័យធម្មការ ស្រុក-ខ័ណ្ឌ ផង ។ ទាំងការបោះឆ្នោតជ្រើសរើសក៏ដូចជាការដកហូតងារសមាជិកណាម្នាក់ ត្រូវតែធ្វើការប្រជុំគណៈសង្ឃ ដោយមានការចូលរួមពី មន្ត្រីធម្មការនិងសាសនា ស្រុក-ខ័ណ្ឌ ហើយធ្វើកំណត់ហេតុត្រឹមត្រូវមានចុះហត្ថលេខា ចៅអធិការ និង មន្ត្រីធម្មការ ស្រុក-ខ័ណ្ឌ ប្រថាប់ត្រារួចបញ្ជូនតាមរយៈ សង្កាត់-ឃុំ ស្រុក-ខ័ណ្ឌ ទៅមន្ទីរធម្មការនិងសាសនា ខេត្ត-ក្រុង ដើម្បី ចេញសេចក្ដីសំរេច ។

<u>ប្រការដែលគួរជៀសវាងជាដាច់ខាត</u> :

- អាចារ្យ.អាចារ្យរងនិងគណៈកម្មការ ដែលប្រព្រឹត្តមិនប្រក្រតីបង្កឱ្យមានបញ្ហាផ្សេង ៗ មិនអនុញ្ញាត្តិឱ្យឈរឈ្មោះបោះឆ្នោតលើកទី ២ ទៀតទេ ។
- អាចារ្យនិងគណៈកម្មការដល់ផុតអាណត្តិត្រូវឈប់ជាស្វ័យប្រវត្តិ ។
- អាចារ្យ-គណៈកម្មការមិនអនុញ្ញាត្តឱ្យយកគ្រួសារឬញាត្តិមិត្តទៅស្នាក់នៅទីអាវាសវត្តបានឡើយ ។
- មហាដាច់ខាតការប្រមូលពុទ្ធបរិស័ទ ពីកន្លែងផ្សេងៗ ពុំមែនអ្នកជើងវត្តនោះមកបោះឆ្នោត ឬ ឈរឈ្មោះឱ្យគេបោះឆ្នោត ។
- ហាមការបង្កើតជា ពួក ក្រុម ដែលបង្កភាពមិនប្រក្រតីនៅក្នុងវត្ត ។
- មិនត្រូវធ្វើអ្វីដែលផ្ទុយពីវិន័យរបស់ព្រះពុទ្ធបរមគ្រូ នៃយើង និងច្បាប់រដ្ឋឡើយ ។

សារាចរ-សារាចរណែនាំទាំងឡាយដែលមានខ្លឹមសារផ្ទុយពីនេះ ត្រូវទុកជានិរាករណ៍ ។

អាស្រ័យហេតុនេះ សូមលោកនាយក លោកស្រីនាយិការ មេត្តាទទួលអនុវត្តនូវសារាចរនេះ ឱ្យមានប្រសិទ្ធិភាពខ្ពស់ ។

សូមអស់លោក លោកស្រី ទទួលនូវសេចក្ដីរាប់អានដ៏ស្មោះ អំពីខ្ញុំ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០១

រដ្ឋមន្ត្រី ក្រសួងធម្មការ និង សាសនា

ជា-សារឿន

<u>ចំលង ថ្វាយ-ប្រគេន-ជូន</u>

-សម្ដេចព្រះសង្ឃរាជទាំងពីរគណៈ
-អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋាន រដ្ឋសភា
-ខុទ្ទកាល័យ ព្រះមហាក្សត្រ
-ខុទ្ទកាល័យ សម្ដេចនាយករដ្ឋមន្ត្រី
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-គ្រប់សាលា ខេត្ត-ក្រុង

<u>ដើម្បីថ្វាយ-ជូនជ្រាប</u>

-ព្រះមេគណគ្រប់ ខេត្ត-ក្រុង
-ព្រះអនុគណគ្រប់ ស្រុក-ខ័ណ្ឌ
-អភិបាលគ្រប់ ស្រុក-ខ័ណ្ឌ

( <u>ដើម្បីសហការអនុវត្តន៍</u> )

-ឯកសារ . កាលប្បវត្តិ